# ស្ថានទូតអូស្ត្រាលី
# ភ្នំពេញ
# សេចក្តីប្រកាសព័ត៌មាន

# ពលរដ្ឋអូស្ត្រាលីរៃអង្គាសប្រាក់ដើម្បីជួយ
# ដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្សនៅកម្ពុជា

លោកស្រី **ហ្វីយ៉ូណា ខូឆូ** (Fiona Cochaud) ភារធារីស្ថានទូតអូស្ត្រាលីប្រចាំរាជធានីភ្នំពេញបាន រៀបចំពិធីទទួលស្វាគមន៍មួយ នៅស្ថានទូតអូស្ត្រាលី ចំពោះការមកដល់រាជធានីភ្នំពេញរបស់អ្នកជិះកង់ ចំនួន២២រូប មកពីប្រទេសអូស្ត្រាលី និង សហរដ្ឋអាមេរិកដែលបានជិះកង់ឆ្លងកាត់ប្រទេសកម្ពុជាដើម្បីរៃ អង្គាសថវិការសំរាប់ជួយបង្កើនការយល់ដឹងជាសារធារណៈស្តីពីអំពើរជួញដូរមនុស្ស និងការរំលោភបំពាន ផ្លូវភេទលើស្ត្រីនិងកុមារ ។

ការធ្វើដំណើរដោយជិះកង់អស់រយៈពេលពីរសប្តាហ៍នេះ បានឆ្លងកាត់ប្រទេសវៀតណាមនិងកម្ពុជា ដោយឆ្លងកាត់ចំងាយផ្លូវចំនួន៥៩០គីឡូម៉ែត រៀបចំឡើងដោយអង្គការការសំឡឹងឆ្ពោះទៅអនាគត (The Look 2 the Future Organisation) ដែលជាផ្នែកមួយនៃគំរោងអនាគតទី១០របស់ខ្លួន ។ ស្ថាបនិកនៃអង្គ ការការសំឡឹងឆ្ពោះទៅអនាគត លោកស្រី **ស្ទីហ្វេនី ឡូរ៉េនហ្ស៊ូ** (Stephanie Lorenzo) បានចូលរួមនិងដឹក នាំការធ្វើដំណើរដោយជិះកង់នេះផងដែរ ។

កាលពីឆ្នាំ២០០៩ គំរោងអនាគតទី១ មានអ្នកជិះកង់ចំនួន២១រូបហើយរៃអង្គាសប្រាក់បានជាង US$ ៧៩,០០០ ។ នៅឆ្នាំនេះ មានអ្នកជិះកង់ចំនួន២២រូបបានធ្វើដំណើរក្នុងតំបន់ហើយរៃអង្គាសប្រាក់បានចំនួន US$១៥០,០០០ ដើម្បីផ្តល់ជូនមូលនីធិសូមាលីម៉ម សំរាប់គំរោងបង្កើនការយល់ដឹងស្តីពីអំពើរជួញដូរមនុស្ស ដែលជាបទល្មើសមួយក្នុងចំណោមឧក្រិដ្ឋកម្មឆ្លងដែនពិភពលោកដ៏ទៃទៀត ។ លោកស្រី **ហ្វីយ៉ូណា ខូឆូ** ភារធារីស្ថានទូតអូស្ត្រាលី និង លោកស្រី **ស្ទីហ្វេនី ឡូរ៉េនហ្ស៊ូ** បានប្រគល់មូលប្បទានប័ត្រនូវទឹកប្រាក់ ចំនួនUS$១៥០,០០០ ដែលបានមកពីការឧបត្ថម្ភអ្នកជិះកង់ដល់ លោកស្រី **ម៉ម សូម៉ាលី** ស្ថាបនឹកនៃមូល និធិសូមាលីម៉ម នាឱកាសនោះផងដែរ ។

លោកស្រី **ហ្វីយ៉ូណា ខូឆូ** បានមានប្រសាសន៍ថា ពលរដ្ឋក្មេងៗទាំងនេះមានទឹកចិត្តយ៉ាងខ្លាំងក្លា ដោយបានចូលរួមចំណែកដោយផ្ទាល់ខ្លួនរបស់ពួកគេចំពោះបញ្ហាសាកលដ៏ធ្ងន់ធ្ងរមួយ បន្ទាប់ពីពួកគេបាន

អានពីការតស៊ូយ៉ាងក្លាហានរបស់លោកស្រី **ម៉ម សូម៉ាលី** ដែលខ្លួនគាត់ផ្ទាល់ជាអ្នករស់រានមានជីវិតសល់ពីទាសភាពផ្លូវភេទ ។ ខ្ញុំពិតជាមានមោទនភាពណាស់ចំពោះកិច្ចខិតខំប្រឹងប្រែងដ៏អស្ចារ្យរបស់ពួកគេកន្លងមកក្នុងការដើររៃអង្គាសប្រាក់យ៉ាងច្រើនដើម្បីបុព្វហេតុដ៏មានតំលៃនេះ ។

អំពើរជួញដូរស្ត្រី និង កុមារដើម្បីធ្វើអាជីវកម្មផ្លូវភេទឬពលកម្ម គឺជាបញ្ហាយ៉ាងធ្ងន់ធ្ងរមួយដែលកំពុងប្រឈមដោយប្រទេសកំពុងអភិវឌ្ឍដោយរាប់ទាំងប្រទេសកម្ពុជាផងដែរ ។ ប្រទេសអូស្ត្រាលីគាំទ្រដល់គំរោងមួយចំនួននៅក្នុងអនុតំបន់មេគង្គក្នុងគោលបំណងកាត់បន្ថយករណីជួញដូរស្ត្រីនិងកុមារ និងធ្វើអោយប្រសើរឡើងលើកិច្ចការពារ ការព្យាបាល និងការធ្វើសមាហរណកម្មនៃស្ត្រីនិងកុមារដែលទទួលរងនូវអំពើរជួញដូរ ។

តាមរយៈនគរបាលសហព័ន្ធអូស្ត្រាលី (AFP) និង ទីភ្នាក់ងារដើម្បីការអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី (AusAID) ប្រទេសអូស្ត្រាលីបាននិងកំពុងជួយដល់កម្ពុជាក្នុងការពង្រឹងគ្របខ័ណ្ឌច្បាប់ដើម្បីប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដោយរាប់បញ្ចូលទាំង អំពើររត់ពន្ធនិងជួញដូរមនុស្ស និងទេសចរណ៍ផ្លូវភេទកុមារ ។ នគរបាលសហព័ន្ធអូស្ត្រាលី (AFP) និងទីភ្នាក់ងារដើម្បីការអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី (AusAID) កំពុងតែធ្វើការសហការយ៉ាងសកម្មជាមួយក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី ក្នុងកិច្ចការពារជនរងគ្រោះនៃអំពើរជួញដូរមនុស្ស និង ការបង្កើនការយល់ដឹងសារធារណៈស្តីពីអំពើរជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើស្ត្រីនិងកុមារ ។

ព័ត៌មានបន្ថែម សូមទំនាក់ទំនង:
លោកស្រី **ហ្វីយ៉ូណា ខុឆូ** ស្ថានទូតអូស្ត្រាលី ភ្នំពេញ
ទូរស័ព្ទលេខ: ០២៣ ២១៣ ៤៧០
ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១០